# រឿងសោមាភិក្ខុនី (បិដក៣០ ទំព័រ៤)

## (ដកស្រង់ពី បិដក អដ្ឋកថា ដីកា)



រៀបរៀងនិងប្រែដោយ ភិក្ខុ សារត្ថធម្មោ ទួន សាវ៉េត ព.ស២៥៦៧, គ.ស២០២៣

# សេចក្តីផ្តើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និងបដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្តីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សាបដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្តីសុខ សេចក្តីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្តីសុខ សេចក្តីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

*វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី១៣ ខែវិច្ឆិកាឆ្នាំ២០២៣*

ភិក្ខុសារត្ថធម្មោ នួន សារ៉េត

## សោមាសូត្រ ទី២ (មិជក)

[៤] សាវត្ថីនិទាន។ គ្រានោះ សោមាភិក្ខុនី ស្លៀកស្បង់ ប្រដាប់បាត្រ និង ចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកពីបិណ្ឌបាត ក្នុងបច្ឆាភត្ត ក៏ដើរសំដៅទៅកាន់អន្ធវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅដល់អន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ។

[៥] គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យ សេចក្ដីតក់ស្លុត និងសេចក្ដីព្រឺរោម ឲ្យកើតឡើងដល់សោមាភិក្ខុនី ប្រាថ្នាឲ្យនាងឃ្លាតចាកសមាធិ ក៏ចូលទៅរកសោមាភិក្ខុនី លុះចូលទៅដល់ហើយ ក៏ពោលគាថានឹងសោមាភិក្ខុនីថា ទី [ព្រះអរហត្ត។] ណា ដែលមានដោយកម្រ ជាទីដែលឥសីទាំងឡាយ គប្បីដល់ ទីនោះស្ត្រីដែលមានបញ្ញាប្រវែងពីរធ្នាប់ មិនអាចនឹងដល់បានឡើយ។

[៦] លំដាប់នោះ សោមាភិក្ខុនី មានសេចក្ដីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស បានជាពោលនូវគាថា។ ទើបសោមាភិក្ខុនី មានសេចក្ដីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យ សេចក្ដីតក់ស្លុត និងសេចក្ដីព្រឺរោម ឲ្យកើតឡើងដល់អាត្មាអញ ប្រាថ្នាឲ្យអាត្មាអញ ឃ្លាតចាកសមាធិ បានជាពោលនូវគាថា។ លុះសោមាភិក្ខុនី ដឹងច្បាស់ថា

នេះជាមារមានចិត្តបាបហើយ ក៏ពោលគាថាទាំងឡាយនឹងមារមានចិត្តបាបថា កាលបើចិត្ត របស់ស្ត្រីភាពដែលឃើញនូវធម៌ [ចតុសច្ចធម៌ ឬខន្ធបញ្ចកៈ ជាអារម្មណ៍នៃវិបស្សនា។] ដោយប្រពៃ បានតាំងមាំហើយ [ចិត្តដែលតាំងនៅក្នុងសមាធិ។] កាលបើញាណ [ផលសមាបត្តិញ្ញាណ។] កំពុងប្រព្រឹត្តទៅ ស្ត្រីភាពនឹងធ្វើអ្វី (ក៏ធ្វើបាន) បើបុគ្គលណា មានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញជាស្ត្រី ឬជាបុរស ឬមួយមានកង្វល់ថា អាត្មាអញ មាន ដូច្នេះ មារគួរនឹងស្តីថា ឲ្យបុគ្គលនោះបាន។

លំដាប់នោះ មារមានចិត្តបាបដឹងថា សោមាភិក្ខុនី ស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះឯង។

(ចប់បិដក)

# អដ្ឋកថា

## សោមាសូត្រទី ២

*ក្នុងសោមាសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤] *បទថា* ***ហាន៎*** *បានដល់ ព្រះអរហត្ត ។ បទថា* ***ទុរភិសម្ភវំ*** *បានដល់ បានដោយក្រ ។ បទថា* ***ទ្វង្គុលប្បញ្ញាយ*** *បានដល់ បញ្ញាតិចតួច ម្យ៉ាងទៀត ស្ត្រីឈ្មោះថា* ***ទ្វង្គុលប្បញ្ញាយ*** *បានដល់ ព្រោះប្រើម្រាមដៃពីរចាប់សំឡីកប្បាសវៃជាអំបោះ ។*

[៦] *បទថា* ***ញាណម្ហិ វត្តមានម្ហិ*** *សេចក្តីថា កាលញាណក្នុងផលសមាបត្តិប្រព្រឹត្តទៅហើយ ។ បទថា* ***ធម្មំ វិបស្សតោ*** *សេចក្តីថា អ្នកឃើញច្បាស់ធម៌ គឺ សច្ចៈ ៤ ឬឃើញចំពោះបញ្ចក្ខន្ធ ដែលជាអារម្មណ៍របស់វិបស្សនាក្នុងចំណែកខាងដើម ។ បទថា* ***កិញ្ចិ វាបន អស្មីតិ*** *ឬមានសេចក្តីកន្ទល់ថាអាត្មាអញមាន ដូច្នេះ សេចក្តីថា ឬសេចក្តីកន្ទល់ដទៃៗ នឹងគប្បីមានដល់បុគ្គលណា ដោយតណ្ហា មានះ និងទិដ្ឋិថា ជាយើង ដូច្នេះ ។*

**ចប់អដ្ឋកថា សោមាសូត្រទី ២**

# សោមសូត្រទី២ (ដីកាចារ្យ)

(៤) បទថា ឋានៈ មានសេចក្តីថា ខាងក្នុងវិស័យនៃឋានៈជាឥស្សរៈ (ជាធំ)។ ព្រោះភាវៈនៃការកំហែងដ៏អាក្រក់ មិនសមគួរ ។

ក្នុងបទនេះថា ប្រាកដដោយម្រាមដៃទាំងពីរ មានសេចក្តីថា ស្ត្រីទាំងឡាយ ចាប់ផ្តើមតាំងអំពីកាលខ្លួនជាកុមារិកាក្រមុំមក បានតាំងនៅតាមលំដាប់វិធីចំអិនបាយ ហើយចាក់ទឹកក្នុងឆ្នាំង ហើយកំដៅនូវអង្ករ សូម្បីរើរឡើងហើយនូវការត្រេកអរនោះ ដើម្បីកាត់បង់នូវប្រមាណនៃកាលឆ្អិនអង្ករនោះ ដោយការបិទរបស់ខ្លួន ក៏មិនអាចចេះវិធីចំអិនឲ្យឆ្អិនបាន ដោយត្រឹមតែការកាន់យកសណ្ឋាននៃពណ៌បាន ចាំបាច់អ្វីដល់ការចេះក្នុងការគាប់ដោយដៃម្រាមទាំងពីរ ។ ព្រោះហេតុនោះ ទើបលោកពោលថា ប្រាកដដោយម្រាមដៃទាំងពីរ ព្រោះបញ្ញាអន់ត្រឹមតែពីរចំអាម ។ ការនៅដោយមិនវង្វេង រមែងប្រាកដក្នុងសច្ចៈបួន ដោយការប្រព្រឹត្តទៅមិនដាច់នៃផលសមាបត្តិញ្ញាណ ទើបលោកពោលថា ពីរបទនេះថា ការប្រព្រឹត្តទៅក្នុងញាណ មានសេចក្តីថា ការប្រព្រឹត្តទៅក្នុងផលសមាបត្តិញាណ ។

បទថា កាលឃើញ មានសេចក្តីថា កាលដែលខ្លួនឃើញនូវបញ្ចក្ខន្ធដោយវិសេសអំពីការត្រាស់ដឹងមិនវង្វេងមក និងការដែលខ្លួនឃើញនូវបញ្ចក្ខន្ធដោយវិសេសក្នុងខាងដើមអំពីការត្រាស់ដឹងសច្ចៈពិត ។

ពីរបទថា ដទៃទៀត មានសេចក្ដីថា នូវវត្ថុណាមួយដទៃអំពីស្ត្រីនិងបុរស ។

ពីរបទថា ជាអញ មានសេចក្ដីថា ក្នុងវត្ថុជាគ្រហស្ថដោយការកាន់យកនូវមានៈ ទិដ្ឋិ និងតណ្ហាមែនពិត ហើយពោលថា ដោយអំណាចនៃ តណ្ហា មានៈ ទិដ្ឋិ ថាជាអញ ។

សោមាសុត្តវណ្ណនា ចប់